Seattle Office of Labor Standards

# ឯកសារបញ្ជាក់ការពិតពីបទបញ្ញត្តិការពារអ្នកម៉ៅការឯករាជ្យ

អត្ថបទបកប្រែនៃឯកសារនេះ អាចទទួលបានតាមការស្នើសុំតាមរយៈ៖ (206) 256-5297 ។



បទបញ្ញត្តិការពារអ្នកម៉ៅការឯករាជ្យរបស់ទីក្រុង សៀងថល តម្រូវអង្គភាពធានារ៉ាប់រងជួលអ្នកធ្វើការ ឱ្យផ្តល់អ្នកម៉ៅការឯករាជ្យនូវពត៌មានច្បាស់លាស់មុនពេលចុះកិច្ចសន្យាហើយនិងនៅពេលទទួលការបង់ប្រាក់។ អ្នកម៉ៅការឯករាជ្យត្រូវតែបានទទួលការបង់ប្រាក់នៅឬមុនកាលបរិច្ឆេទកំណត់ទូទាត់ការបង់ប្រាក់ យោលក្រោមលក្ខខណ្ឌនៃកិច្ចសន្យា ក្រោមលក្ខខណ្ឌនៃការបញ្ចេញពត៌មានលម្អិតមុនចុះកិច្ចសន្យា ឬក្នុងរយៈពេល 30 ថ្ងៃ។ ច្បាប់នេះនឹងចាប់ផ្តើមអនុវត្តនៅថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2022។

## ការធានារ៉ាប់រង

### តើបុគ្គលិកណាខ្លះត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

អ្នកម៉ៅការឯករាជ្យគឺជាអ្នកមានក្រុមហ៊ុនប្រកបមុខរបរដោយខ្លួនឯងដែលត្រូវបានអង្គភាពជួលមកធ្វើការដើម្បីផ្តល់សេវាកម្មឬយកកំរៃ។ ច្បាប់នេះគឺសំដៅទៅលើអ្នកម៉ៅការឯករាជ្យទាំងអស់ ដោយមានករណីលើកលែង[1] មួយចំនួនដូចបានរាយនៅខាងក្រោម។

### តើក្រុមហ៊ុនណាខ្លះត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

ច្បាប់នេះសំដៅទៅលើអង្គភាពជួលអ្នកធ្វើការ ដែលចូលរួមជាទៀងទាត់ក្នុងសកម្មភាពប្រកបអាជីវកម្មឬពាណិជ្ជកម្ម រួមទាំងអាជីវកម្មមិនស្វែងរកប្រាក់ចំណេញផងដែរ។

តើកុងត្រាមួយណាត្រូវបានធានារ៉ាប់រងដោយច្បាប់នេះ?

ច្បាប់នេះធានារ៉ាប់រងលើកុងត្រាដោយយោលទៅតាមប្រភេទនៃសេវាកម្មនិងតម្លៃនៃសេវាកម្មរបស់ពួកគេ។

- **ប្រភេទនៃសេវាកម្ម**
  - ការងារដែលធ្វើនៅទីក្រុង សៀងថល
  - អង្គភាពជួលដឹង/មានហេតុត្រូវដឹងអំពីការងារដែត្រូវធ្វើនៅទីក្រុង សងថល
- **$ តម្លៃនៃសេវាកម្ម**
  - កិច្ចសន្យាច្រើនជាង ៦០០ ដុល្លារ
  - កិច្ចសន្យាអាចប្រមូលផ្តុំរួមលើសពីមួយឆ្នាំ

---

[1] អ្នកម៉ៅការឯករាជ្យដែលមិនត្រូវបានធានារ៉ាប់រងដោយច្បាប់នេះគឺមេធាវី ក្នុងស្ថានការណ៍ដែលអ្នកម៉ៅការឯករាជ្យមានទំនាក់ទំនងជាមួយអង្គភាពជួលអ្នកធ្វើការ មានកំណត់លើកិច្ចព្រមព្រៀងទាក់ទងនិងថ្លៃជួលកន្លែងប្រកបមុខរបរ (ឧទាហរណ៍ដូចជា អ្នកសម្អាងសក់ ជួលតូបមួយកន្លែងនៅហាងសម្ផស្ស ជាដើម) និងអ្នកម៉ៅការឯករាជ្យផ្សេងទៀត ដែលត្រូវបានកំណត់ដោយច្បាប់របស់នាយកដ្ឋានដឹកនាំស្តង់ដាច្បាប់ការងារ។ ដំណើរនៃការបង្កើតច្បាប់ត្រូវបានគេរំពឹងថា នឹងកើតឡើងនៅដើម/ពាក់កណ្តាលឆ្នាំ 2022។ សូមចុះឈ្មោះដើម្បីទទួលអត្ថបទពត៌មានពី OLS Newsletter ឬចំពោះការធ្វើបច្ចុប្បន្នភាព សូមចូលមើលគេហទំព័ររបស់ OLS តាមរយៈ៖ www.seattle.gov/laborstandards ។



*ឯកសារនេះផ្តល់ការពន្យល់អំពីច្បាប់។ សូមសម្គាល់ថា៖ ពត៌មានដែលផ្តល់ដោយក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ មិនមែនជាការទូន្មានផ្នែកច្បាប់ បង្កើតការសម្រេចចិត្តរបស់ភ្នាក់ងារ ឬបង្កើតសិទ្ធិរវាងមេធាវីនិងអតិថិជនជាមួយអ្នកអានទេ។ នេះមិនគួរយកមកប្រើជំនួសច្បាប់និងបទបញ្ញត្តិទេ។*

តម្រូវការ

## តម្រូវការបង់ប្រាក់ឱ្យបានទៀងពេលវេលា

អង្គភាពជួលអ្នកធ្វើការ ត្រូវតែផ្តល់ "ការបង់ប្រាក់ឱ្យបានទៀងពេលវេលា" ដល់អ្នកម៉ៅការឯករាជ្យ ដូចខាងក្រោម៖

1) លក្ខខណ្ឌនៃកិច្ចសន្យា

2) លក្ខខណ្ឌនៃពត៍មានលម្អិតមុនចុះកិច្ចសន្យា ឬ

3) ក្នុងរយៈពេល 30 ថ្ងៃ។

## តម្រូវការបញ្ចេញពត៍មានឱ្យបានដឹងឮ

អង្គភាពជួលអ្នកធ្វើការ ត្រូវតែបញ្ចេញពត៍មានទៅអ្នកម៉ៅការឯករាក្យនៅខាងក្រោមទាំងអស់ ឱ្យបានដឹងឮមុនពួកគេចុះឈ្មោះទទួលកិច្ចសន្យា និងពេលវេលាទូទាត់បង់ថ្លៃសេវាកម្ម *លើកលែងតែ*អ្នកបើកបរឱ្យបណ្តាញក្រុមហ៊ុន (ឧទាហរណ៍ដូចជា អ្នកបើកបរ Uber និង Lyft ជាដើម)។ ក្នុងរយៈប៉ុន្មានខែខាងមុខនេះ OLS នឹងបញ្ចេញគំរូដែលអង្គភាពជួលអ្នកធ្វើការ អាចយកមកប្រើការដើម្បីផ្តល់ព័ត៍មាននេះ — ចំពោះការធ្វើបច្ចុប្បន្នភាព សូមចូលមើលគេហទំព័ររបស់យើងនៅទីនេះ។

ក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារប្រចាំទីក្រុងស៊ីឯថល

បេសកកម្មរបស់យើងគឺលើកកម្ពស់ស្តង់ដារការងារតាមរយៈការផ្តល់មតិយោបល់យ៉ាងលម្អិតពីសហគមន៍និងអាជីវកម្ម ការអនុវត្តយុទ្ធសាស្រ្ត និងការអភិវឌ្ឍន៍គោលនយោបាយប្រកបដោយភាពច្នៃប្រឌិត ដោយសន្យាផ្តល់នូវយុត្តិធម៌ជាតិសាសន៍និងសង្គម។

សេវាកម្មរបស់យើង

ការស៊ើបអង្កេតលើពាក្យបណ្តឹង

ការផ្សព្វផ្សាយដល់អាជីវករ

ជំនួយបច្ចេកទេសសម្រាប់អាជីវកម្ម

ធនធាននិងការណែនាំ

មានសេវាកម្មបកប្រែភាសា។ មានការសម្របសម្រួលផ្តល់ជូនជនពិការ។ មានផ្តល់សេវាកម្មដោយគឺឥតគិតថ្លៃ។

ព័ត៍មានបន្ថែម

ទូរស័ព្ទមកលេខ៖

(206) 256-5297

អ៊ីមែល៖ laborstandards@seattle.gov

ចូលមើល៖ seattle.gov/laborstandards

### 1. តម្រូវការបញ្ចេញពត៍មានឱ្យបានដឹងឮមុនទទួលកិច្ចសន្យា

| | |
|---|---|
| ▪ *កាលបរិច្ឆេទ* | ▪ *មូលដ្ឋានបង់ប្រាក់* |
| ▪ *ឈ្មោះរបស់អ្នកម៉ៅការឯករាជ្យ* | ▪ *ច្បាប់ចែកលុយទឹកតែនិង/ ឬថ្លៃផ្តល់សេវាកម្ម* |
| ▪ *ឈ្មោះអង្គភាពជួលអ្នកធ្វើការ + ព័ត៍មានទំនាក់ទំនង* | ▪ *ការចំណាយប្រាក់លើការងារនិងការចំណាយណាមួយដែលអង្គភាពជួលអ្នកធ្វើការត្រូវសងប្រាក់ចំណាយនោះមកវិញ* |
| ▪ *ការពិពណ៌នាអំពីការងារ* | ▪ *ការកាត់កង ថ្លៃសេវា ឬថ្លៃចំណាយ* |
| ▪ *ទីតាំងការងារ* | ▪ *កាលវិភាគនៃការទូទាត់បង់ប្រាក់* |
| ▪ *អត្រានៃការបង់ប្រាក់ខែ* | |

### 2. រយៈពេលតម្រូវការបញ្ចេញពត៍មានទូទាត់បង់ប្រាក់

| | |
|---|---|
| ▪ *កាលបរិច្ឆេទ* | ▪ *របៀបចែក លុយទឹកតែ ប្រាក់ទូទាត់ និង/ ឬ ថ្លៃសេវាកម្ម* |
| ▪ *ឈ្មោះរបស់អ្នកម៉ៅការឯករាជ្យ* | ▪ *មូលដ្ឋានបង់ប្រាក់* |
| ▪ *ឈ្មោះអង្គភាពជួលអ្នកធ្វើការ* | ▪ *ការទូទាត់សងថ្លៃចំណាយវិញដោយអង្គភាពជួលធ្វើការ* |

ក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារប្រចាំទីក្រុងស៊ីឯថល

*ឯកសារនេះផ្តល់ការពន្យល់អំពីច្បាប់។ សូមសម្គាល់ថា៖ ពត៍មានដែលផ្តល់ដោយក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ មិនមែនជាការទូន្មានផ្នែកច្បាប់ បង្កើតការសម្រេចចិត្តរបស់ភ្នាក់ងារ ឬបង្កើតសិទ្ធិរវាងមេធាវីនិងអតិថិជនជាមួយអ្នកអានទេ។ នេះមិនគួរយកមកប្រើជំនួសច្បាប់និងបទបញ្ញត្តិទេ។*

Seattle Office of Labor Standards

- *ការពិពណ៌នាអំពីសេវាកម្មដែលស្ថិតក្រោមការបង់ថ្លៃចំណាយ*
- *ការទូទាត់បង់ប្រាក់សរុប*
- *ទីតាំងនៃសេវាកម្មដែលត្រូវបង់ថ្លៃចំណាយ*
- *ការកាត់កង*
- *អត្រានៃការបង់ប្រាក់ខែ*
- *ប្រាក់ខែក្រោយពីបានកាត់កងរួច*

### ធនធាននានា

ចំពោះព័ត៌មានតាមក្រោយទៀត សូមចូលមើលគេហទំព័ររបស់យើង ឬចុះឈ្មោះដើម្បីទទួលអត្ថបទព័ត៌មានរបស់យើងតាមរយៈ៖ www.seattle.gov/laborstandards។

សូមអានបន្ថែមអំពីបទបញ្ញត្តិស្ដីពីការការពារអ្នកម៉ៅការឯករាជ្យនៅទីនេះ៖

http://www.seattle.gov/laborstandards/ordinances/independent-contractor-protections-



*ឯកសារនេះផ្តល់ការពន្យល់អំពីច្បាប់។ សូមសម្គាល់ថា៖ ព័ត៌មានដែលផ្តល់ដោយក្រសួងត្រួតពិនិត្យស្តង់ដារច្បាប់ការងារ មិនមែនជាការទូន្មានផ្នែកច្បាប់ បង្កើតការសម្រេចចិត្តរបស់ភ្នាក់ងារ ឬបង្កើតសិទ្ធិរវាងមេធាវីនិងអតិថិជនជាមួយអ្នកអានទេ។ នេះមិនគួរយកមកប្រើជំនួសច្បាប់និងបទបញ្ញត្តិទេ។*